អេស៊ីលីដា
ACLEDA UNIVERSITY

របាយការណ៍
ប្រចាំឆ្នាំ ២០២៣-២០២៤

មាតិកា

១. ប្រវត្តិសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ធនធានសិក្សា និងធនធានរូបវន្ត ១

២. គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ និងទស្សនវិជ្ជា..... ៥

៣. របាយការណ៍ក្រុមប្រឹក្សាភិបាល.....៧

៤. រចនាសម្ព័ន្ធ.....១២

៥. ការទទួលស្គាល់គុណភាពអប់រំ.....១៧

៦. កិច្ចព្រមព្រៀង/សហប្រតិបត្តិការ.....១៩

៧. ការចុះឈ្មោះចូលសិក្សា ២២

៨. ហិរញ្ញវត្ថុ.....២៧

៩. សេវានិស្សិត.....២៩

១០. កិច្ចការសិក្សា ៣៦

ប្រវត្តិសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ធនធានសិក្សា និងធនធានរូបវន្ត

ប្រវត្តិសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ឆ្នាំ១៩៩៣ រហូតដល់ ឆ្នាំ១៩៩៧ ជានាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឹន លោក **ម៉ែន សារ៉ន្ត** ជានាយកនាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឹន។ (ឆ្នាំ១៩៩៣ ជាក្រុមគាំទ្របច្ចេកទេស របស់អង្គការ លីដា និងឆ្នាំ១៩៩៧ ប្រែក្លាយជានាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឹន នៃអេស៊ីលីដា មីក្រូហិរញ្ញវត្ថុ)។

ឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០០១ ជាមជ្ឈមណ្ឌលហ្វឹកហ្វឹន លោក **ម៉ែន សុផល** ជានាយកមជ្ឈមណ្ឌលហ្វឹកហ្វឹន។ ខែមករា ឆ្នាំ១៩៩៨ នាយកដ្ឋានប្រឹក្សា និងការហ្វឹកហ្វឹន ត្រូវបានធ្វើការផ្លាស់ប្តូរឈ្មោះជាមជ្ឈមណ្ឌលហ្វឹកហ្វឹន ដោយស្ថិតក្រោមនាយកដ្ឋានឥណទាន នៃស្ថាប័នមីក្រូហិរញ្ញវត្ថុអេស៊ីលីដា។ ថ្ងៃទី០១ ខែមករា ឆ្នាំ២០០១ មជ្ឈមណ្ឌលហ្វឹកហ្វឹន ត្រូវបានប្តូរមកជាផ្នែកហ្វឹកហ្វឹន នៃនាយកដ្ឋានឥណទាន នៃធនាគារ អេស៊ីលីដា លីមីធីត (ធនាគារឯកទេស)។

ឆ្នាំ២០០១ ដល់ ឆ្នាំ២០១០ ជានាយកដ្ឋានហ្វឹកហ្វឹន លោក **ថោង ចាន់តារា** ជានាយកនាយកដ្ឋានហ្វឹកហ្វឹន។ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ដើម្បីរៀបចំទៅតាមការវិវឌ្ឍរបស់ធនាគារ អេស៊ីលីដា ស្របតាមផែនការអាជីវកម្មរបស់ខ្លួន មជ្ឈមណ្ឌលបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន ត្រូវបានអនុញ្ញាតឲ្យធ្វើប្រតិបត្តិការដាច់ដោយឡែកជាថ្មីម្តងទៀតពី ធនាគារ អេស៊ីលីដា ភីអិលស៊ី។

ឆ្នាំ២០១១ ដល់ ឆ្នាំ២០១៧ ជាអេស៊ីលីដា ត្រេននីង សេនធ័រ លោក **ឆន ពន្លឺ** ជាអគ្គនាយកស្តីទី ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុនធនាគារ អេស៊ីលីដា ភីអិលស៊ី ។ អេស៊ីលីដា ត្រេននីង សេនធ័រ ត្រូវបានទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ ក្រោមអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ: Co. ១៣៣២KH/២០១១ ដែលមានដើមទុនសរុបចំនួន ២០,០០០,០០០ (ម្ភៃលានរៀល) ដែលកម្មសិទ្ធិនៃភាគទុនិកគឺ ធនាគារ អេស៊ីលីដា ភីអិលស៊ី។ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈអនុក្រឹត្យលេខ: ១៣ អនក្រ.បក ។

ឆ្នាំ២០១៨ ដល់ បច្ចុប្បន្ន បណ្ឌិត ផុន ណារិន ជាសាកលវិទ្យាធិការ ។ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមអនុក្រឹត្យលេខ: ២៧ អនក្រ.បក។

ធនធានសិក្សា

ធនធានសិក្សា គឺជាចំណែកមួយដ៏សំខាន់ក្នុងការគាំទ្រសេវាអប់រំរបស់គ្រឹះស្ថានសិក្សាមួយ ដែលជាកត្តាជំរុញលើកទឹកចិត្ត គ្រូបង្រៀន និស្សិត និងកម្មករនិយោជិត ឱ្យមានការចូលរួម និងចូលចិត្តការសិក្សា និងការបង្រៀនរបស់ខ្លួន។ សាកលវិទ្យាល័យ បានរៀបចំធនធានសិក្សាដោយបានសាងសង់បណ្ណាល័យដែលមានទំហំធំទូលាយ មានក្រឡាផ្ទៃសរុបចំនួន ២៣៨៨ ម៉ែត្រ. ក្រឡា បំពាក់ឧបករណ៍ សម្ភារ បរិក្ខាគ្រប់គ្រាន់យ៉ាងសម្បូរបែប ដូចជាសៀវភៅ ម៉ាស៊ីនខ្ចី-សងស្វ័យប្រវត្តិ កុំព្យូទ័រ ប្រព័ន្ធអ៊ីនធឺណិត ប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិក (E-Library) ម៉ាស៊ីនថតចម្លង។ល។ និងបានរៀបចំតាមបន្ទប់សិក្សា បន្ទប់អនុវត្តកុំព្យូទ័រ ដែលបំពាក់នូវធនធានបច្ចេកវិទ្យា សម្ភារឧបទ្ទេសគ្រប់គ្រាន់ មានដូចជាប្រព័ន្ធ អ៊ីនធឺណិតល្បឿនលឿន LCD Projector កុំព្យូទ័រ។ល។ ដើម្បីផ្តល់ឱកាស និងសម្រួលដល់គ្រូបង្រៀន និស្សិត និងកម្មករនិយោជិតរបស់ខ្លួនឱ្យទទួលបានភាពងាយ ស្រួលក្នុងការសិក្សាស្រាវជ្រាវឯកសារ និងទិន្នន័យផ្សេងៗ ដើម្បីគាំទ្រការបង្រៀន ការសិក្សា និងការងារឱ្យទទួលបានជោគជ័យ ប្រកបដោយគុណភាព។

ធនធានរូបវន្ត

សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានអគាររដ្ឋបាល អគារសិក្សា បណ្ណាល័យ បន្ទប់ប្រជុំ សាលសហសិក្សា ដែលមានទីតាំងធំទូលាយ មានបរិស្ថានសិក្សាល្អអំណោយផលម្រាប់ការសិក្សា និងសកម្មភាពផ្សេងៗ។

សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានអាសយដ្ឋានស្ថិតនៅអគារលេខ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលជាទីតាំងប្រកបដោយ បរិស្ថានល្អ អំណោយផលដល់ការបង្រៀន និងការសិក្សា និងមានទីធ្លាធំទូលាយ។ សាកលវិទ្យាល័យមានអគារសិក្សា បន្ទប់សិក្សា ការិយាល័យ បន្ទប់ប្រជុំ សាលសហសិក្សា បណ្ណាល័យ បន្ទប់ថតចម្លង បន្ទប់គិលានុបដ្ឋាយិកា បន្ទប់បម្រើអតិថិជន បន្ទប់វិសោធនកម្ម អាហារដ្ឋាន កន្លែងលក់ទំនិញ សម្ភារសិក្សា បេឡា ទីកន្លែងបម្រើសេវាធនាគារអេឡិចត្រូនិច បន្ទប់ត្រួតពិនិត្យកាមេរ៉ា(CCTV) និងការផ្គត់ផ្គង់អគ្គិសនី និងទឹកគ្រប់គ្រាន់ហើយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានផ្ទៃដីទំហំសរុប ៧៥.៧៥0 ម^{២} ដែលមានអគារសិក្សាចំនួន ២អគារ កម្ពស់ ៥ជាន់ (ទំហំសរុប ១១.៩៨0,៨0 ម^{២}) អគាររដ្ឋបាល មានចំនួន១អគារ កម្ពស់ពាជាន់(ទំហំសរុប ៦.៣៧៧,២៤ ម^{២}) អគារ អន្តេវាសិកដ្ឋាន មានចំនួន១អគារ កម្ពស់៤ជាន់ (ទំហំសរុប ១.៧៦៤ ម^{២}) អគារបណ្ណាល័យ មានចំនួន១អគារ កម្ពស់ពាជាន់ (ទំហំសរុប ២.៣៨៨ ម^{២})។

ក្រោមការវិនិយោគដែលមានទំហំទឹកប្រាក់ប្រមាណ ៣៧លានដុល្លារសហរដ្ឋអាមេរិក សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានសាងសង់អគារថ្មីលើដីទំហំ ៧៥.៧៥0 ម៉ែត្រក្រឡា ដែលមានទីតាំងនៅ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានអគារសិក្សាចំនួន២អគារ កម្ពស់៥ជាន់ (បន្ទប់សិក្សារបស់និស្សិត Class Room ចំនួន២៩ បន្ទប់ប្រជុំចំនួន៧ សាលសហសិក្សា (Theather Room) ចំនួន១0 បន្ទប់កុំព្យូទ័រចំនួន៧ បន្ទប់សម្រាប់និស្សិតសិក្សាម្នាក់ឯង/សិក្សាជាក្រុម /Seminar Room ចំនួន៣៤ បណ្ណាល័យចំនួន១អគារ កម្ពស់ពាជាន់ បរិវេណទីធ្លាសម្រាប់កីឡា បាល់ទាត់ទំហំ ៦៤មx១00ម បាល់ទះ ទំហំ ២១មx៣៤ម បាល់បោះទំហំ ២១មx៣៤ម បន្ទប់សិល្ប: ទិវាវប្បធម៌ និងសកម្មភាពផ្សេងៗទំហំ ៥មx២៥ម អន្តេវាសិកដ្ឋានចំនួន៤៨បន្ទប់ អាចឱ្យនិស្សិតស្នាក់នៅចំនួន១៤៧នាក់ និងអគារសម្រាប់បុគ្គលិករដ្ឋបាលចំនួន១អគារ កម្ពស់ពាជាន់ ដែលអាចឱ្យបុគ្គលិកបំពេញការងារប្រហែល២៥0កន្លែង។

បន្ទប់សិក្សានៅសាកលវិទ្យាល័យមានលក្ខណ:ទូលាយ និងបានបង្កបរិយាកាសរៀនសូត្រយ៉ាងប្រសើរ ទៅតាមភាពបត់បែននៃវិធីសាស្ត្របង្រៀន ដោយរក្សាបាននូវភាពស្ងប់ស្ងាត់ ពន្លឺ និងខ្យល់អាកាសចេញ-ចូលគ្រប់គ្រាន់ ព្រមទាំងបានបំពាក់នូវអ៊ីនធឺណិត ពាក្យស្លោកអប់រំ រូបភាពនានា និងសម្ភារឧបទ្ទេសន៍សម្រាប់ដំណើរការបង្រៀន និងសិក្សា។

ក្រៅពីសិក្សាក្នុងថ្នាក់ និស្សិតក៏អាចមកសិក្សារៀនសូត្របន្ថែមនៅក្នុងបណ្ណាល័យ ដែលមានបំពាក់ឧបករណ៍ អេឡិចត្រូនិច រួមមាន៖ កុំព្យូទ័រ ឧបករណ៍ស្តាប់សម្លេង និងសេវាអ៊ីនធឺណិត។ល។ សាកលវិទ្យាល័យបានរៀបចំបន្ទប់សម្រាប់សាស្ត្រាចារ្យដែលសម្រួលដល់ការត្រៀមរៀបចំជាមុននូវកិច្ចការបង្រៀន ការស្រាវជ្រាវ ឯកសារ កំណែកិច្ចការនិស្សិត ផែនការមេរៀន និងការសម្រាកជាដើម។ លើសពីនេះ សាកលវិទ្យាល័យក៏មាននូវបន្ទប់សាលសហសិក្សាចំនួន ៣៤បន្ទប់ សម្រាប់ជាទីកន្លែងសិក្សារៀបចំសិក្ខាសាលា ការធ្វើបទបង្ហាញដែលទាក់ទងទៅនឹងចំណេះដឹងសង្គម និងវិទ្យាសាស្ត្រ ដើម្បីចែករំលែកចំណេះដឹងបទពិសោធន៍ និងលើកទឹកចិត្តដល់ការចូលរួមក្នុងសកម្មភាពសិក្សារបស់និស្សិត ដែលអាចផ្ទុកសិស្ស-និស្សិត ពី៤៥-២១៨នាក់។

A U B

គតិពេចន៍ ចក្ខុវិស័យ បេសកកម្ម គោលដៅនិង គុណតម្លៃ និងទស្សនវិជ្ជា

គតិពេចន៍

ថ្នាលអប់រំដើម្បីភាពជោគជ័យក្នុងអាជីព។

ចក្ខុវិស័យ

សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាថ្នាលអប់រំធុរកិច្ចប្រកបដោយគុណភាពឈានមុខ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងតំបន់។

បេសកកម្ម

បេសកកម្មរបស់ **សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា** គឺផ្តល់នូវសេវាកម្មអប់រំ បណ្តុះបណ្តាល តាមរយៈការសិក្សាផ្ទាល់ជាមួយសាកលវិទ្យាល័យ និងបែបឌីជីថល ដើម្បីអភិវឌ្ឍ៖ **ចំណេះដឹង ជំនាញវិជ្ជាជីវៈ ភាពច្នៃប្រឌិត និងនវានុវត្តន៍ បទពិសោធ អភិសមាចារ បណ្តាញទំនាក់ទំនង ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ** ដើម្បីជោគជ័យក្នុងអាជីពរបស់អ្នកសិក្សា ដោយប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ សីលធម៌វិជ្ជាជីវៈ សង្គម វប្បធម៌ចម្រុះ ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត។

គោលដៅ

កសាងសមត្ថភាពនិស្សិតដែលបានបញ្ចប់ការសិក្សា មានសក្តានុពលការងារខ្ពស់។

គុណតម្លៃ និងទស្សនវិជ្ជា

គុណភាព គណៈគ្រប់គ្រង និងសាស្ត្រាចារ្យ មានសមត្ថភាពខ្ពស់ទាន់សម័យ, សេវាកម្មទាន់ចិត្តប្រកបដោយគុណភាព, វិធីសាស្ត្របង្រៀនមានប្រសិទ្ធភាព, សិក្ខូបករណ៍ទំនើបទាន់សម័យ នាំឱ្យនិស្សិតមានគុណភាពឈានមុខ។

ក្រមសីលធម៌ និស្សិតប្រតិបត្តិឥតខ្ចោះក្នុងជីវិត និងការងារ ស្របតាមច្បាប់ គោលការណ៍ សីសធម៌ ប្រពៃណីក្នុងសង្គម និងមានក្រមសីលធម៌ធុរកិច្ច ខ្ពស់បំផុត។

ការងារ និស្សិតមានសមត្ថភាព លទ្ធភាព ទទួលបាននូវការងារព្រមទាំងបង្កើត បង្កើន និងរក្សាបាននូវនិរន្តរភាពការងារ។

វិជ្ជាជីវៈ និស្សិតមានសមត្ថភាពក្នុងវិជ្ជាជីវៈ ច្បាស់លាស់ ប្រកបដោយតម្លៃនៃគុណធម៌សិក្សា ស្របតាមបទដ្ឋានជាខ្នាតគំរូ ទាន់សម័យ។

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំគ្នាផ្ទាល់ចំនួន ៤លើក ក្នុងឆ្នាំ២០២៣ និង ជួបជុំគ្នាចំនួន ៣លើក ក្នុងឆ្នាំ២០២៤ ក្នុងខែតុលា ខែមីនា ខែមិថុនា ខែកញ្ញា និងខែធ្នូ នៅក្នុងរាជធានីភ្នំពេញ។ លើសពីនេះទៅទៀត គិតត្រឹមខែតុលា ឆ្នាំ២០២៤ សេចក្តីសម្រេច ជាច្រើនត្រូវបានអនុម័តតាមរយៈអ៊ីមែល។ កិច្ចប្រជុំនីមួយៗជាធម្មតាមានរយៈពេល១ថ្ងៃ រួមបញ្ចូលទាំងប្រជុំគណៈកម្មាធិការផងដែរ។

សមាសភាពៈ

លោកស្រី ភូរិ រតនា

ប្រធានក្រុមប្រឹក្សាភិបាល

លោក Pieter Kooi

អភិបាល

លោកស្រី ម៉ារ អមរា

អភិបាល

បណ្ឌិត ផុន ណារិន

អភិបាល

លោក ម៉ាច់ ធារី

អភិបាល

លោកស្រី ភូរិ រតនា, ប្រធានក្រុមប្រឹក្សាភិបាល

ជនជាខ្មែរ កើតនៅឆ្នាំ១៩៧២។ លោកស្រី ភូរិ រតនា ទទួលបានសញ្ញាបត្រថ្នាក់ក្រោយបរិញ្ញាបត្រ (DEA) និងជាបេក្ខជនបណ្ឌិតជំនាញឧស្សាហកម្មសេដ្ឋកិច្ច បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ ជំនាញពាណិជ្ជកម្មបរទេស និងបរិញ្ញាបត្រជាន់ខ្ពស់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យប៉ារីស១ Panthéon-Sorbonne។

លោកស្រី ភូរិ រតនា ជាប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចាប់តាំងពីខែធ្នូ ឆ្នាំ២០២២។ លោកស្រីបានចូលជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែវិច្ឆិកា ឆ្នាំ២០២១។

លោកស្រី មានបទពិសោធ២៥ឆ្នាំ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ ការអភិវឌ្ឍវិស័យឯកជន និងហិរញ្ញវត្ថុ។ លោកស្រីមានប្រវត្តិឆ្នើមជាទីប្រឹក្សា/អ្នកសេដ្ឋកិច្ច រួមទាំងមានបទពិសោធផ្ទាល់នៅក្នុងតួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់។ បច្ចុប្បន្ន លោកស្រីគឺជាទីប្រឹក្សាជាន់ខ្ពស់សម្រាប់ការវិនិយោគ និងវិស័យឯកជន ឱ្យអង្គការអន្តរជាតិផ្សេងៗ និងជាក្រុមប្រឹក្សា ផ្តល់យោបល់ដល់សហគ្រាសខ្មែរ អ៊ីមផេកហាប់ និងស្មុលវើល។ លោកស្រី គឺជាអភិបាលឯករាជ្យនៅធនាគារពាណិជ្ជមួយនៅកម្ពុជារបស់លោកស្រីមានជាអាទ៍ អភិបាលប្រតិបត្តិ EuroCham Cambodia ចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២។ តួនាទីកន្លងមកនៅប្រទេសកម្ពុជារបស់លោកស្រីមានជាអាទ៍ អភិបាលប្រតិបត្តិ EuroCham Cambodia ចាប់ពីឆ្នាំ២០១៨ ដល់២០១៨ ទីប្រឹក្សាធុរកិច្ចនៅ DFDL ដៃគូនៅ Private equity firm Cambodia Emerald នៅឆ្នាំ២០០៨ និងជាអភិបាលនៅ CCFC (French Cambodian Chamber of Commerce)។ លោកស្រីធ្លាប់បម្រើការងារនៅប្រទេសស្វីស ក្នុងតួនាទីជាអ្នកគ្រប់គ្រងផលបត្រ នៅធនាគារឯកជនមួយ និងជាអ្នកសេដ្ឋកិច្ចនៅ UNCTAD។

លោកស្រី រតនា បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការកសាងសមត្ថភាព និងឧត្តមភាពក្នុងវិស័យ អប់រំ ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុ។ បន្ថែមលើនេះ លោកស្រី គឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៅ Cambodia Community of Investment Professionals (សមាគម CFA នៅកម្ពុជា) ដើម្បីបណ្តុះបណ្តាលជំនាញក្នុងស្រុកផ្នែកហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់កម្ពុជាឱ្យក្លាយជាគោលដៅវិនិយោគ។ ការប្រកួតប្រជែងស្រាវជ្រាវ CFA នៅកម្ពុជាបានក្លាយជាការប្រកួតប្រជែងដែលត្រូវបានទទួលស្គាល់ក្នុងគោលបំណងបណ្តុះបណ្តាលក្រុមនិស្សិតសាកលវិទ្យាល័យក្នុងជំនាញហិរញ្ញវត្ថុថ្មីៗ ដូចជាការវាយតម្លៃសមធម៌ជា ដើម។ លើសពីនេះ អ្នកស្រីតែងតែចូលរួមជាវាគ្មិន និងជាអ្នកណែនាំក្នុងការប្រកួតប្រជែងទាក់ទងនឹងអាជីវកម្មជាតិ និងអន្តរជាតិជាច្រើន រួមទាំងការប្រកួតប្រជែងដូចជា SmartSpark ជាដើម។

លោកស្រី ម៉ារ អមរា, អភិបាល

ជនជាតិខ្មែរ កើតនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៦៧ និងបានចូលបម្រើការនៅ អេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៣។ លោកស្រី ម៉ារ អមរា ជាសមាជិកក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ហើយលោកស្រីក៏ជាសមាជិកគណៈកម្មាធិការសវនកម្ម សីលធម៌ និងជាអ្នកសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល (ACECO) នៅខែធ្នូ ឆ្នាំ២០២២។

លោកស្រីបានបញ្ចប់វគ្គសិក្សាស្តីពី កម្មវិធីប្រតិបត្តិសញ្ញាបណ្ណបៃតង និងនិរន្តរភាពហិរញ្ញវត្ថុ ពីទីក្រុងស្ពុកខុល ប្រទេសស៊ុយអែត ក្នុងខែតុលា ឆ្នាំ២០២២ និងភាពជាអ្នកដឹកនាំស្តាប័នពីHarvard Business School ប្រទេសអាមេរិក ក្នុងខែសីហា ឆ្នាំ២០២២ និងបានបញ្ចប់វគ្គសិក្សា ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ក្នុងឆ្នាំ២០១៨ ហើយលោកស្រីបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រងក្នុងឆ្នាំ២០០៣។ ក្រៅពីនោះនៅមានវគ្គសិក្សាជាច្រើនដូចជា គណនេយ្យគ្រប់គ្រង គណនេយ្យហិរញ្ញវត្ថុ និងសវនកម្ម នៅសាកលវិទ្យាល័យ Regent ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ នៅក្នុងរាជធានីភ្នំពេញ។

បច្ចុប្បន្នលោកស្រីជាអនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងគណៈប្រធាននាយិកាប្រតិបត្តិការ លោកស្រីក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្ម ប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម។ លោកស្រីជាប្រធានគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម និងជាគណៈកម្មាធិការគ្រប់គ្រងការវិនិយោគ និងជាសមាជិកគណៈកម្មាធិការឥណទានប្រតិបត្តិ។ លោកស្រីក៏ជាអ្នកដឹកនាំការងារ Basel Team ផងដែរ។

លោកស្រីគ្រប់គ្រងលើ នាយកដ្ឋានហិរញ្ញវត្ថុ, នាយកដ្ឋានរៀបចំ និងត្រួតពិនិត្យផែនការថវិកា, នាយកដ្ឋានវិនិយោគសាធារណៈ, នាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានគ្រប់គ្រងសេវាឥណទាន, នាយកដ្ឋានសេវាហិរញ្ញវត្ថុ, នាយកដ្ឋានផែនការយុទ្ធសាស្ត្រ, ការិយាល័យហិរញ្ញប្បទានពាណិជ្ជកម្ម, និងការិយាល័យគណនេយ្យគ្រប់គ្រង។

លោកស្រីទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ។ ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីរួមមាន៖ ជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យ៉ូរ៉ីធី ភីអិលស៊ី និងជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃអេស៊ីលីដា ហ្វាយណាន់ហ្សូល ត្រាស់។

លោក Pieter Kooi, អភិបាល

ជនជាតិហុលង់ដ៍ កើតក្នុងឆ្នាំ១៩៥៨ លោក Pieter Kooi បានចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចាប់ពីខែមីនា ឆ្នាំ២០១៦ (បច្ចុប្បន្នជា សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា)។ លោកក៏ជាប្រធានគណៈកម្មាធិការ សវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

ចាប់ពីឆ្នាំ១៩៩៣ លោកជាទីប្រឹក្សា មីក្រូហិរញ្ញវត្ថុ អេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្ចាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ។ ចាប់ពីឆ្នាំ១៩៩៩ លោក Pieter Kooi បានបម្រើការងារជាទីប្រឹក្សា មីក្រូហិរញ្ញវត្ថុរយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូយ៉ក។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោក Pieter Kooi បានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជា សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា), និងក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក។ បច្ចុប្បន្ន លោកធ្វើជាក្រុមប្រឹក្សាភិបាលជាច្រើន នៅក្នុងសម្ព័ន្ធធនាគារ អេស៊ីលីដា។

លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហុលង់ដ៍។ លោកក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

លោក ម៉ាច់ ធារី, អភិបាល

ជនជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៦៥ ។ លោក ម៉ាច់ ធារី បានចូលបម្រើការងារជាសមាជិកក្រុមប្រឹក្សាភិបាលនៃ សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅខែធ្នូ ឆ្នាំ២០២២។ លោកទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ជំនាញ វិទ្យាសាស្ត្រកុំព្យូទ័រ និងស្ថិតិ ពីសាកលវិទ្យាល័យ Monash ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៨៩។ បន្ទាប់មកលោកបានបន្តការសិក្សា ផ្នែកប្រព័ន្ធអាជីវកម្ម (Business Systems) និងបានទទួលសញ្ញាបត្រក្នុងឆ្នាំ១៩៩០ ពីសាកលវិទ្យាល័យដដែល។ លោកបាន បម្រើការងារឱ្យអង្គការ ស្ថាប័នជាច្រើន ដូចជា ធនាគារ ANZ ក្នុងប្រទេសអូស្ត្រាលី សាកលវិទ្យាល័យ Monash, UNHCR ប្រចាំ ប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកកម្ពុជា អង្គការពលកម្មអន្តរជាតិ មុនចាប់ផ្តើមចូលបម្រើការងារសមាជិកក្រុមប្រឹក្សា ភិបាលនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

បច្ចុប្បន្ន លោកជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា ជាប្រធានគណៈកម្មាធិការ IT Steering និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិ, សមាជិកនៃគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល និងសមាជិកនៃ គណៈកម្មាធិការផ្សេង ទៀតនៃធនាគារ អេស៊ីលីដា ភីអិលស៊ី។

បណ្ឌិត ផុន ណារិន, អភិបាល

បណ្ឌិត ផុន ណារិន កើតនៅឆ្នាំ១៩៦៩។ លោកបណ្ឌិតបានទទួលសញ្ញាបត្របណ្ឌិត ស្រាវជ្រាវ ឯកទេសរដ្ឋបាលធុរកិច្ចពីសាកល វិទ្យាល័យបៀលប្រាយនៅក្នុងឆ្នាំ២០១៦។ លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ ចំរើន ពហុបច្ចេកវិទ្យានៅក្នុងឆ្នាំ២០០៨ និងទទួលសញ្ញាបត្រវិទ្យាសាស្ត្ររដ្ឋបាលពីវិទ្យាស្ថានរដ្ឋបាលសាធារណៈ (IPA) នៅឆ្នាំ១៩៩២ ពីប្រទេសថៃឡង់ដ៍ ហើយលោកទទួលបានសញ្ញាបត្រពីវិទ្យាស្ថានអូស្ត្រាលី(AICD) នៅក្នុងឆ្នាំ២០១២ និងបានបញ្ចប់សាស្ត្រាចារ្យ Professor of First Cycle of Secondary Education ក្នុងឆ្នាំ ១៩៩០ ប្រទេសថៃឡង់ផងដែរ។

លោកបណ្ឌិត ណារិន គឺជាគ្រូបង្រៀននៅវិទ្យាល័យរយៈពេល ០៧ឆ្នាំ (១៩៨៨-១៩៩៥)។ ចាប់ពីឆ្នាំ១៩៩៦ លោកបណ្ឌិតបានចូល រួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនស្តីពី មីក្រូហិរញ្ញវត្ថុ សហគ្រាសធុនតូច និងមធ្យម ការគ្រប់គ្រងធនធានមនុស្ស និង ធនាគារនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស រួមមានប្រទេសថៃឡង់ដ៍ ឡាវ វៀតណាម មីយ៉ាន់ម៉ា ចិន ហូឡង់ អូស្ត្រាលី ហ្វីលីពីន ទីក្រុងប៉ារីស ប្រទេសបារាំង និងប្រទេសប្រ៊ុយណេ ដារូសាឡឹម ចាប់ផ្តើមនៅឆ្នាំ ១៩៩៦។ លោកបណ្ឌិត ក៏ជាអ្នកសម្របសម្រួល កម្មវិធីឥណទានជនបទរបស់អង្គការអេស៊ីលីដា ជាមន្ត្រីលើកកម្ពស់សហគ្រាសធុនតូច (SEPO) ជាជំនួយការឥណទានមិនមាន ទ្រព្យធានា ជាជំនួយការឥណទានមានទ្រព្យធានា ជាប្រធានភ្នាក់ងារឥណទាន ជាប្រធានការិយាល័យស្រុក ជានាយកសាខាខេត្ត តាកែវ និងជានាយកប្រតិបត្តិរងនាយកដ្ឋានឥណទាន ធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាល រាជធានីភ្នំពេញ។ ចាប់ ពីខែធ្នូ ឆ្នាំ២០០៨ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គនាយកធនាគារ អេស៊ីលីដា ឡាវ។ លោកបណ្ឌិត ផុន ណារិន ក៏ជា សមាជិកក្រុមប្រឹក្សាភិបាលតំណាងធនាគារ អេស៊ីលីដា ឡាវ និងជាសមាជិកនៃ គណៈកម្មាធិការឥណទាន។ ក្រៅពីតួនាទីរបស់ លោកនៅក្នុង ធនាគារ អេស៊ីលីដា លោកបណ្ឌិតក៏ជាសមាជិកសភាពាណិជ្ជកម្ម (AMCHAM Laos) និងជាសមាជិកនៃ សមាគមន៍ធនាគារឡាវ និងជាសមាជិកនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មឡាវ។

លោកបណ្ឌិត ផុន ណារិន បានកាន់តំណែងជាអគ្គនាយកធនាគារ អេស៊ីលីដា ឡាវ រយៈពេល៩ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងត្រូវបានតែងតាំងជានាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤។ ចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់បច្ចុប្បន្ន លោកបានក្លាយជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

គណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល
វិសាលភាព និងគោលបំណង

គណៈកម្មាធិការសិក្សាធិការ ត្រូវបានបង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់កិច្ចការសិក្សាធិការ លើការបង្រៀន ការរៀន និងការកំណត់ចក្ខុវិស័យលើគុណភាពនៃការអប់រំ រួមទាំងការអភិវឌ្ឍសមត្ថភាព និងរៀបចំកម្មវិធីសិក្សាផងដែរ។

សមាសភាព

- បណ្ឌិត ឌី សមស៊ីដេត ប្រធាន
- បណ្ឌិត Pieter Kooi សមាជិក
- លោក ម៉ាច់ ធារី សមាជិក (តំណាងសាស្ត្រាចារ្យ)
- បណ្ឌិត ផុន ណារិន សមាជិកអចិន្ត្រៃយ៍ (Ex-Officio member)

គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល
វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល ត្រូវបានបង្កើតឡើងដោយ ក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីតាមដាន និងត្រួតពិនិត្យភាពត្រឹមត្រូវនៃ របាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងការផ្តល់សេវារបស់សវនករខាងក្រៅ។ ក្រៅពីនេះ ដើម្បីធានាការអនុលោមស្របទៅនឹងច្បាប់ និងបទប្បញ្ញត្តិនានា ដែលសមស្របទៅនឹងគោលនយោបាយ ដើម្បីផ្តល់នូវស្តង់ដារកម្រិតខ្ពស់បំផុតនៃអភិបាលកិច្ចសាជីវកម្ម និងប្រតិបត្តិដោយក្រមសីលធម៌។

សមាសភាព

- បណ្ឌិត Pieter Kooi ប្រធាន
- អ្នកស្រី ម៉ារ អមរ៉ា សមាជិក

កិច្ចប្រជុំគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល បានបើកកិច្ចប្រជុំផ្ទាល់ ៤លើកក្នុងឆ្នាំ២០២៣ និងឆ្នាំ២០២៤ ដោយផ្ទាល់។

បញ្ហាចម្បង និងសកម្មភាពចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ ខែតុលា ឆ្នាំ២០២៤

- ធ្វើការត្រួតពិនិត្យលើគោលនយោបាយនៃក្រុមប្រឹក្សាភិបាល
- ធានាឱ្យបាននូវភាពត្រឹមត្រូវនៃប្រតិបត្តិការរបស់សាកលវិទ្យាល័យ ស្របទៅនឹងច្បាប់ និងបទបញ្ញត្តិ
- ធ្វើការតាមដាន និងត្រួតពិនិត្យនៃដំណើរការរបស់ស្ថាប័ន ស្របទៅតាមគោលនយោបាយ គោលការណ៍ប្រតិបត្តិ និងនីតិវិធី ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការប្រតិបត្តិសាកលវិទ្យាល័យ
- ពង្រឹងទំនាក់ទំនងភាពជាដៃគូរ ជាមួយអាជ្ញាធរ និងដៃគូរពាក់ព័ន្ធ ដើម្បីធានាឱ្យសាកលវិទ្យាល័យ អនុលោមទៅតាមបច្ចុប្បន្នកម្មនៃបទបញ្ញត្តិដែលមានផលប៉ះពាល់ដល់ប្រតិបត្តិការណាមួយរបស់សាកលវិទ្យាល័យ
- តាមដានរាល់ហានិភ័យនៃការមិនប្រតិបត្តិតាមបទបញ្ញត្តិ ដែលអាចកើតមានឡើងនៅពេលអនាគត
- ត្រួតពិនិត្យ និងផ្តល់យោបល់លើចំណុចខ្លាំង និងខ្សោយ នៃរបាយការណ៍ស្វ័យវាយតម្លៃ ដើម្បីធ្វើឱ្យគុណភាពអប់រំត្រូវបានទទួលស្គាល់ដោយ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (ACC) ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត
- ពិនិត្យលើការអនុលោមគោលនយោបាយកំណាពារនិវេទនជន និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង
- ពិនិត្យ និងឆ្លើយតបទៅលើការស្នើសុំនានារបស់ក្រុមប្រឹក្សាភិបាល
- ពិភាក្សា និងពិនិត្យទៅលើលិខិតសវនករខាងក្រៅ (Management Letter) និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង
- ធ្វើការវាយតម្លៃគុណភាពនៃនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសក្នុងការវាស់ស្ទង់ និងការគ្រប់គ្រងហានិភ័យឱ្យមានភាពសមស្របគ្នា និងបានផ្តល់អនុសាសន៍ក្នុងការដោះស្រាយ
- ត្រួតពិនិត្យ ពីប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុងរបស់សាកលវិទ្យាល័យ និងធ្វើការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ

រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា (ស.ព.ស)



គណៈកម្មាធិការប្រតិបត្តិ

បណ្ឌិត ផុន ណារិន

សាកលវិទ្យាធិការ សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា

បណ្ឌិត ផុន ណារិន កើតនៅឆ្នាំ១៩៦៩។ លោកបណ្ឌិតបានទទួលសញ្ញាបត្របណ្ឌិតស្រាវជ្រាវ ឯកទេសរដ្ឋបាលធុរកិច្ចពី សាកលវិទ្យាល័យបៀលប្រាយនៅក្នុងឆ្នាំ២០១៦។ លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ ចំរើនពហុបច្ចេកវិទ្យានៅក្នុងឆ្នាំ២០០៤ និងទទួលសញ្ញាបត្រវិទ្យាសាស្ត្ររដ្ឋបាលពីវិទ្យាស្ថានរដ្ឋបាលសាធារណៈ (IPA) នៅឆ្នាំ១៩៩២ ពីប្រទេសថៃឡេងដ៏ ហើយលោកទទួលបានសញ្ញាបត្រពីវិទ្យាស្ថានអូស្ត្រាលី(AICD) នៅក្នុងឆ្នាំ២០១២ និងបានបញ្ចប់សាស្ត្រាចារ្ម Professor of First Cycle of Secondary Education ក្នុងឆ្នាំ ១៩៩០ ប្រទេសថៃឡេងផងដែរ។

លោកបណ្ឌិត ណារិន គឺជាគ្រូបង្រៀននៅវិទ្យាល័យរយៈពេល ០៧ឆ្នាំ (១៩៨៨-១៩៩៥)។ ចាប់ពីឆ្នាំ១៩៩៦ លោកបណ្ឌិតបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនស្តីពីមីក្រូហិរញ្ញវត្ថុ សហគ្រាសធុនតូច និងមធ្យម ការគ្រប់គ្រងធនធានមនុស្ស និងធនាគារនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស រួមមានប្រទេសថៃឡេងដ៏ ឡាវ វៀតណាម មីយ៉ាន់ម៉ា ចិន ហូឡង់ អូស្ត្រាលី ហ្វីលីពីន ទីក្រុងប៉ារីស ប្រទេសបារាំង និងប្រទេសប្រ៊ុយណេ ដារូសាឡឹម ចាប់ផ្តើមនៅឆ្នាំ ១៩៩៦។ លោកបណ្ឌិត ក៏ជាអ្នកសម្របសម្រួលកម្មវិធីឥណទានជនបទរបស់អង្គការអេស៊ីលីដា ជាមន្ត្រីលើកកម្ពស់សហគ្រាសធុនតូច (SEPO) ជាជំនួយការឥណទានមិនមានទ្រព្យធានា ជាជំនួយការឥណទានមានទ្រព្យធានា ជាប្រធានភ្នាក់ងារឥណទាន ជាប្រធានការិយាល័យស្រុក ជានាយកសាខាខេត្តតាកែវ និងជានាយកប្រតិបត្តិរងនាយកដ្ឋានឥណទាន ធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាល រាជធានីភ្នំពេញ។ ចាប់ពីខែធ្នូ ឆ្នាំ២០០៨ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គនាយកធនាគារ អេស៊ីលីដា ឡាវ។ លោកបណ្ឌិត ផុន ណារិន ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលតំណាងធនាគារ អេស៊ីលីដា ឡាវ និងជាសមាជិកនៃគណៈកម្មាធិការឥណទាន។ ក្រៅពី តួនាទីរបស់លោកនៅក្នុង ធនាគារ អេស៊ីលីដា លោកបណ្ឌិតក៏ជាសមាជិកសភាពាណិជ្ជកម្ម (AMCHAM Laos) និងជាសមាជិកនៃសមាគមន៍ធនាគារឡាវ និងជាសមាជិកនៃ សភាពាណិជ្ជកម្ម និងឧស្សាហកម្មឡាវ។

លោកបណ្ឌិត ផុន ណារិន បានកាន់តំណែងជាអគ្គនាយកធនាគារ អេស៊ីលីដា ឡាវ រយៈពេល៩ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និងត្រូវបានតែងតាំងជានាយកវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤។ ចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់បច្ចុប្បន្ន លោកបានក្លាយជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

លោក ហុង ហោម្មលី

សាកលវិទ្យាធិការរង និងជាប្រធានហិរញ្ញវត្ថុ

លោក ហុង ហោម្មលី កើតនៅឆ្នាំ១៩៨០ លោកមានចំណង់ចំណូលចិត្តផ្នែកហិរញ្ញវត្ថុ នៅឆ្នាំ២០០២ លោកទទួលបានសញ្ញាប័ត្រផ្នែកច្បាប់ មិនយូរប៉ុន្មានលោកបានបន្ថែមជំនាញគណនេយ្យតាមរយៈការសិក្សាបន្ថែមថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំ២០០៣ បន្ទាប់មកលោកទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសហិរញ្ញវត្ថុនៅក្នុងឆ្នាំ ២០១១ នៃស្ថាប័នល្បីមួយនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្នលោកបានបញ្ចប់កម្មវិធីសិក្សា ACCA នៅសាលារៀនខេមអេដ។

វិថីអាជីពរបស់ លោក ហុង ហោម្មលី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង្ហាញពីការយកចិត្តទុកដាក់ ចាប់ផ្តើមជាគណនេយ្យករក្នុងឆ្នាំ២០០៣ លោកទទួលបានការយកចិត្តទុកដាក់ រីកចម្រើនយ៉ាងឆាប់រហ័សតាមរយៈតួនាទីគណនេយ្យ និងសវនកម្មផ្សេងៗ ទេពកោសល្យរបស់លោក ត្រូវបានទទួលស្គាល់យ៉ាងខ្លាំងដោយបានឈានទៅដល់ការកាន់មុខតំណែងនាពេលបច្ចុប្បន្នជាសាកលវិទ្យាធិការរង និងជាប្រធានហិរញ្ញវត្ថុនៃ សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា។

លើសពីអាជីពរបស់លោក ដែលភាពជាអ្នកដឹកនាំ យ៉ាងស្ទាត់ជំនាញផ្នែកយុទ្ធសាស្ត្រ នៅឆ្នាំ២០០៥ លោក ហុង ហោម្មលី បានក្លាយជាសមាជិកនៃក្រុមបណ្តុះបណ្តាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី លោកបានចូលរួមចែករំលែកបទពិសោធន៍ជាច្រើនទៀតលើកម្មវិធីបណ្តុះបណ្តាលគ្របដណ្តប់លើប្រធានបទជាច្រើន ចាប់ពីជំនាញគណនេយ្យ និងហិរញ្ញវត្ថុ រហូតដល់ការអភិវឌ្ឍន៍ផែនការអាជីវកម្ម និងសវនកម្មហិរញ្ញវត្ថុ។

លោក រដ្ឋ រតនៈ

សាកលវិទ្យាធិការរង និងជាប្រធានសិក្សាធិការ

លោក រដ្ឋ រតនៈ មានអាជីពគួរឲ្យចាប់អារម្មណ៍ខ្លាំងទាំងផ្នែកអប់រំ និងអាជីវកម្ម ដោយនាំមកនូវបទពិសោធន៍ដ៏សម្បូរបែបដល់មុខតំណែងបច្ចុប្បន្នជាសាកលវិទ្យាធិការរង និងជាប្រធានសិក្សាធិការ នៅសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

លោកមានប្រវត្តិសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអាជីវកម្ម ឯកទេសគ្រប់គ្រងទូទៅពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បន្ថែមដោយបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញទីផ្សារ ពីវិទ្យាស្ថានជាតិគ្រប់គ្រង។ ការយកចិត្តទុកដាក់របស់គាត់ចំពោះការអភិវឌ្ឍន៍វិជ្ជាជីវៈ គឺបង្ហាញឱ្យឃើញបន្ថែមទៀតតាមរយៈការចូលរួមក្នុងវគ្គសិក្សាជាច្រើនទាំងក្នុងស្រុក និងបរទេសដូចជា ការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល និងការបណ្តុះបណ្តាលឯកទេសលើការរៀបចំ និងការអភិវឌ្ឍន៍កម្មវិធីសិក្សា ការភ្ជាប់លទ្ធផលសិក្សា ការបង្រៀននិងការវាយតម្លៃ ផែនការផ្អែកលើលទ្ធផល និងក្របខណ្ឌM&E និងការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងរបស់CEOប្រកបដោយប្រសិទ្ធភាព កម្មវិធីសិក្សាផ្អែកលើលទ្ធផល ការអនុវត្តការធានាគុណភាពផ្ទៃក្នុងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា និង PDCA cycle នៃការអប់រំផ្អែកលើលទ្ធផល (OBE)។ លើសពីនេះ លោកបានបញ្ចប់វគ្គបំប៉នគរុកោសល្យ និងវិធីសាស្ត្របង្រៀនសម្រាប់សាលាចំណេះទូទៅពីវិទ្យាស្ថានជាតិអប់រំ។

គន្លងវិជ្ជាជីវៈរបស់លោក រដ្ឋ រតនៈ បង្ហាញពីការប្តេជ្ញាចិត្ត ចំពោះវិស័យអប់រំ។ លោកបានចាប់ផ្តើមដំណើររបស់លោកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជាកន្លែងដែលលោកបានឡើងកាន់តំណែងជានាយកសាខា ដោយបង្ហាញពីភាពជាអ្នកដឹកនាំ និងភាពប៉ិនប្រសប់ក្នុងអាជីវកម្ម។ នៅឆ្នាំ២០១០ លោកបានផ្លាស់ប្តូរចូលក្នុងវិស័យអប់រំ ដោយកាន់មុខតំណែងសំខាន់ៗជាច្រើននៅវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា រួមមាន ប្រធានការិយាល័យទីផ្សារ និងទំនាក់ទំនង ប្រធានដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម នាយករង និងជាប្រធានសិក្សាធិការ និងចុងក្រោយបំផុតជាសាកលវិទ្យាធិការរង និងជាប្រធានសិក្សាធិការ។

បទពិសោធន៍យ៉ាងទូលំទូលាយរបស់លោក រដ្ឋ រតនៈ ក្នុងការសិក្សាថ្នាក់ឧត្តមសិក្សា បូកផ្សំនឹងមូលដ្ឋានគ្រឹះសិក្សាដ៏រឹងមាំ និងការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈ ធ្វើឱ្យលោកក្លាយជាអ្នកដឹកនាំដ៏ពិសេសម្នាក់ ដែលមានសមត្ថភាពចូលរួមរៀបចំអនាគតរបស់សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

ការទទួលស្គាល់គុណភាពអប់រំ

ដើម្បីដឹកនាំ និងធានាឱ្យទទួលបាននូវគុណភាពអប់រំតាមកម្រិតស្តង់ដា និងនិរន្តរភាពនៃការអប់រំឧត្តមសិក្សា សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបង្កើតក្រុមការងារធ្វើស្វ័យវាយតម្លៃ (SAR Team) ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង (IQA Commission) ដែលសមាសភាពទាំងអស់ត្រូវបានចូលរួមអនុវត្តពីគ្រប់មហាវិទ្យាល័យ ការិយាល័យ ដេប៉ាតឺម៉ង់ មជ្ឈមណ្ឌល សាលាក្រោយបរិញ្ញាបត្រ និងមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ និងផ្នែកជំនាញពាក់ព័ន្ធ ដើម្បីកំណត់គោលនយោបាយក្នុងការធានាគុណភាពអប់រំ ការត្រួតពិនិត្យតាមដាន ការវាយតម្លៃជាក់ស្តែងតាមរយៈការវិភាគព័ត៌មាន-ទិន្នន័យនូវឯកសារតម្រូវពាក់ព័ន្ធ ការសន្និដ្ឋានប្រកបដោយភាពត្រឹមត្រូវ ការផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់គុណភាពអប់រំនៃការបណ្តុះបណ្តាល ការរៀបចំរបាយការណ៍ស្វ័យវាយតម្លៃសម្រាប់ដាក់ជូនថ្នាក់មានសមត្ថកិច្ចត្រួតពិនិត្យ ផ្តល់អនុសាសន៍ និងវាយតម្លៃ និងការអនុវត្តផ្សេងៗទៀត ក្នុងន័យទទួលបានលទ្ធផលជោគជ័យទៅតាមការកំណត់នូវ ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់សាកលវិទ្យាល័យ។ ទិសដៅសំខាន់របស់សាកលវិទ្យាល័យ គឺការទទួលបានការទទួលស្គាល់គុណភាពអប់រំដ៏ប្រសើរបំផុតទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក ដើម្បីបង្ហាញដល់ សាធារណៈជន មាតាបិតា ឬអាណាព្យាបាល ក្រុមហ៊ុន សហគ្រាស សហគមន៍ផ្តល់ជំនួយ អង្គការនានា ជាពិសេសសម្រាប់រាជរដ្ឋាភិបាល និងប្រទេសជាតិទាំងមូលថា សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានគណនេយ្យភាពចំពោះ ការអប់រំ មានជំនឿទុកចិត្តចំពោះការផ្តល់សេវាអប់រំ និងបានឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងតម្រូវការទីផ្សារការងាររបស់និស្សិត និងសង្គមជាតិ។

ជាក់ស្តែងសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានរៀបចំប្រព័ន្ធធានាគុណភាពផ្ទៃក្នុងច្បាស់លាស់ ដើម្បីទទួលខុសត្រូវលើការធានាគុណភាពអប់រំ និងការវាយតម្លៃគុណភាពផ្ទៃក្នុង ដោយសាកលវិទ្យាល័យបានប្រើប្រាស់ឧបករណ៍វាយតម្លៃរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) និងឧបករណ៍វាយតម្លៃរបស់គ្រឹះស្ថានមួយចំនួនទៀតសម្រាប់ធ្វើស្វ័យវាយតម្លៃលើប្រព័ន្ធអភិបាលកិច្ច និងដំណើរការបណ្តុះបណ្តាលគ្រប់កម្រិតរបស់សាកលវិទ្យាល័យ។
នៅថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) បានផ្តល់ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិដល់សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលបានបំពេញស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាជាតិ សម្រាប់រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ និងជាមួយគ្នានោះដែរ សាកលវិទ្យាល័យក៏បានរៀបចំរបាយការណ៍ធានាគុណភាពផ្ទៃក្នុងរបស់សាកលវិទ្យាល័យជូនទៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឬ្ធាផងដែរ។

សម្រាប់ការទទួលស្គាល់នូវគុណភាពអប់រំក្នុងកម្រិតណាមួយទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក សាកលវិទ្យាល័យនឹងស្នើសុំវាយតម្លៃគុណភាពអប់រំពីស្ថាប័នមានសមត្ថកិច្ច ទៅតាមផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ។

កិច្ចព្រមព្រៀង/សហប្រតិបត្តិការ

ល.រ	តារាងឈ្មោះស្ថាប័នដៃគូ
១	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី
២	ហ្វឺស ហ្វាយនែន ភីអិលស៊ី
៣	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មហានគរ ម.ក
៤	គ្រឹះស្ថានក្រេដ
៥	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សំរឹទ្ធិស័ក លីមីតធីត
៦	រីសិនហ្វាន់ (ខេមបូឌា)
៧	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លីហ្ហរ
៨	រិទ្ធ សុខា ហ្វាយនែន ម.ក
៩	ខេខេ ហ្វាន់ លីស៊ីង ភីអិលស៊ី
១០	ស្មាយ ហ្វាយនែន ភីអិលស៊ី
១១	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាយម៍ អិមអេហ្វ អិលធីឌី
១២	ចំរើន ម៉ាយក្រូហ្វាយនែន លីមីធីត
១៣	រ៉ាយ ស្មាត ហ្វាយនែន ម.ក
១៤	ក្រេឌីមុយទុយអែលកម្ពុជា (សេអឹមកា)
១៥	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បរិបូរណ៍ ភីអិលស៊ី
១៦	ខាប់ភីថល រុងរឿង ម.ក
១៧	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមិក ភីអិលស៊ី
១៨	ប្រតិបត្តិករឥណទានជនបទ សមាគម គឹម សាន ទ្រទ្រង់ជីវភាពកសិករ
១៩	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អូរ៉ូ ហ្វាយនែនខប ភីអិលស៊ី
២០	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី
២១	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស៊ីធី ភីអិលស៊ី
២២	ក្រុមហ៊ុន តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
២៣	ឌី អេច អិល អិចប្រេស ខេមបូឌា អិលធីឌី
២៤	ប្រតិបត្តិករឥណទានប្រសិទ្ធ
២៥	ក្រុមហ៊ុន លី ហ្ហរ ផេប្រ៉ូ ភីអិលស៊ី
២៦	ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្ហរុិន ម.ក
២៧	ក្រុមហ៊ុន អេច អ អាយ អិន ស៊ី (ខេមបូឌា)
២៨	ក្រុមហ៊ុន ហ្វជ្ជណាអ៊ិនវេសម៉ិន ខូអិលធីឌី
២៩	អ អេច អិម អេស ផនសប ម.ក
៣០	គ្រឹះស្ថាន សិរីឧត្តម មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣១	ក្រុមហ៊ុន អ៊ីនប៊ីសណេស ម.ក
៣២	ធនាគារ ព្រីនស៍ ម.ក
៣៣	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អ៊ូរី ហ្វាយនែន ខេមបូឌា ភីអិលស៊ី

៣៤	ម៉ឌើនីធី ហូលឌីង
៣៥	អ៊ិនធីហ្ត្រេធីត ឡូជីស្ទីក សឺវីស ឯ.ក
៣៦	អេហ្វអាយអាយ & អឹសូស៊ីអេត
៣៧	ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ មេហ្គាលីស៊ីង ភីអិលស៊ី
៣៨	និយ័តករបរធនបាលកិច្ច
៣៩	មេគង្គ ម៉ាយក្រូអ៊ិនស្ទរេន
៤០	ណុងហឹប ហ្វាយនែន (ខេមបូឌា) ម.ក
៤១	ធនាគារ ប្រែសណីយ៍កម្ពុជា ក.អ
៤២	យូជេនេថេក (ខេមបូឌា)
៤៣	អ៊ីស្ត វីង អឌីធីង & ខនសាល់ធីង
៤៤	និយ័តករមូលបត្រកម្ពុជា
៤៥	និយ័តករគណនេយ្យនិងសវនកម្ម
៤៦	អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ)
៤៧	អេកូវីស វីអេសឌីខេ & ផាតនើរ ឯ.ក
៤៨	សមាគមធានារ៉ាប់រងកម្ពុជា
៤៩	វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក)
៥០	វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ
៥១	វិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា
៥២	សហគ្រិនខ្មែរ
៥៣	សាលារៀនជំនាន់ថ្មី នៃវិទ្យាល័យ ព្រះស៊ីសុវត្ថិ
៥៤	សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប
៥៥	វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ សាលាជំនាន់ថ្មី
៥៦	សមាគមន៍ញូវតុនធីឡាយ គ្រុប
៥៧	សាលាហេបភីចន្ទតារានារីព្រែកថ្មីរបស់អង្គការទូតទឹសអាឡេកូល
៥៨	ក្រុមហ៊ុន វេសឡាញ អេឌ្យូខេសិន គ្រុប ខូ អិលធីឌី
៥៩	សាលាអន្តរជាតិ ហ្ត្រេនម៉ោន និងសាលារៀនអារីហ្សូន
៦០	សាលារៀនបញ្ញវន្តអង្គរ
៦១	មីគីវ៉េស្គូល
៦២	សាលាអន្តរជាតិ អេស អាយ អេស
៦៣	THE BLUM CENTER FOR DEVELOPING ECONOMIES AT THE UNIVERSITY OF CALIFORNIA, BERKELEY
៦៤	UNIVERSITAS MULTIMEDIA NUSANTARA, INDONESIA
៦៥	UNIVERSITAS MERDEKA MALANG, INDONESIA
៦៦	Imperial English UK

ការចុះឈ្មោះចូលសិក្សា

១ - តម្រូវការក្នុងការចុះឈ្មោះចូលសិក្សា

សាកលវិទ្យាល័យទទួលឱ្យចូលសិក្សាចំពោះសិស្សដែលមានគុណវុធ្ឍិគ្រប់គ្រាន់ ដូចខាងក្រោម៖

១.១ ថ្នាក់បរិញ្ញាបត្ររង

ក. កម្រិតវប្បធម៌ទូទៅ

- ធ្លាក់ ឬជាប់មធ្យមសិក្សាទុតិយភូមិ ឬ
- ធ្លាក់ ឬជាប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ហើយត្រូវនឹងជំនាញស្នើសុំសិក្សា ឬ
- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់សមមូល ដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច

ខ. ចំណេះដឹងភាសាអង់គ្លេស

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់កម្រិតទូទៅ លើចំណេះដឹងភាសាអង់គ្លេស (General English) ក្នុងគ្រឹះស្ថានដែលមានកម្មវិធីសិក្សាជាភាសាអង់គ្លេសមិនលើសពី ០១ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ការប្រឡង IELTS ដោយមានពិន្ទុចាប់ពី ៣.៥០ ឬ TOEFL ចាប់ពី ៣៥០ (Paper Based) មិនលើសពី ០២ឆ្នាំ ក្រោយកាលបរិច្ឆេទចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រមិនឱ្យលើសពីរយៈពេល០២ឆ្នាំ)។

គ. ចំណេះដឹងគណិតវិទ្យា

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់ជាគ្រូបង្រៀនគណិតវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមិនឱ្យលើសពីរយៈពេល០៣ឆ្នាំ)។

ឃ.ចំណេះដឹងកុំព្យូទ័រ

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់ កុំព្យូទ័រទាន់សម័យ MS Word Excel and Power point (មិនលើស ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញលិខិតបញ្ជាក់)។

១.២ ថ្នាក់បរិញ្ញាបត្រ

ក. កម្រិតវប្បធម៌ទូទៅ

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬ
- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់សមមូល ដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច

ខ. ចំណេះដឹងភាសាអង់គ្លេស

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់កម្រិតទូទៅ លើចំណេះដឹងភាសាអង់គ្លេស (General English) ក្នុងគ្រឹះស្ថានដែលមានកម្មវិធីសិក្សាជាភាសាអង់គ្លេសមិនលើសពី ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ការប្រឡង IELTS ដោយមានពិន្ទុចាប់ពី ៣.៥០ ឬ TOEFL ចាប់ពី ៣៥០ (Paper Based) មិនលើសពី ២ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រមិនឱ្យលើសពីរយៈពេល០៣ឆ្នាំ)។

គ. ចំណេះដឹងផ្នែកគណិតវិទ្យា

- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនគណិតវិទ្យាកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមិនឱ្យលើសពីរយៈពេល០៣ឆ្នាំ)។

ឃ.ចំណេះដឹងកុំព្យូទ័រ

- មានសញ្ញាបត្រកុំព្យូទ័រទាន់សម័យ MS Word Excel and Power point (មិនលើស ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញលិខិតបញ្ជាក់)។

១.៣ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ក. កម្រិតវប្បធម៌ទូទៅ

- បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ដោយទទួលបានពិន្ទុGPA លើសពី ២.៥ ដោយមានសញ្ញាបត្រ ឬលិខិតបញ្ជាក់សមមូល ដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច

ខ. ចំណេះដឹងភាសាអង់គ្លេស

- មានសញ្ញាបត្រ ឬលិខិតបញ្ជាក់បានបញ្ចប់ថ្នាក់កម្រិតទូទៅ លើចំណេះដឹងភាសាអង់គ្លេស (General English) ក្នុងគ្រឹះស្ថានដែលមានកម្មវិធីសិក្សាជាភាសាអង់គ្លេសមិនលើសពី ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ការប្រឡង IELTS ដោយមានពិន្ទុចាប់ពី ៥.០០ ឬ TOEFL ចាប់ពី ៥០០ (Paper Based) មិនលើសពី ២ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬ
- មានលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅសាលាមធ្យមសិក្សារដ្ឋ ឬ ឯកជន (ក្នុងករណីសញ្ញាបត្រលើសរយៈពេល០១ឆ្នាំ)។

គ. ចំណេះដឹងកុំព្យូទ័រ

- មានសញ្ញាបត្រកុំព្យូទ័រទាន់សម័យ Advance Excel (មិនលើស ០១ឆ្នាំ ក្រោយកាលបរិច្ឆេទចេញលិខិតបញ្ជាក់)។

២ - ការទទួលឱ្យចូលសិក្សាថ្នាក់បំប៉ន

២.១ ការទទួលឱ្យចូលសិក្សា ដោយឆ្លងកាត់វិសោធនកម្ម

ករណីមិនបំពេញបានទៅនឹងគុណវុធ្ឍិដូចបានរៀបរាប់នៅចំណុចខាងលើ សិស្ស និស្សិតអាចធ្វើវិសោធនកម្មលើចំណេះដឹងភាសាអង់គ្លេស ឬអាចស្នើសុំរៀនបំប៉នភាសាអង់គ្លេសដោយស្វ័យប្រវត្តិ ។ និស្សិតនឹងត្រូវបែងចែកឱ្យសិក្សាទៅតាមកម្មវិធី ដែលបានកំណត់ដោយមហាវិទ្យាល័យសិល្ប: មនុស្សសាស្ត្រ និងភាសា អាស្រ័យលើលទ្ធផលវិសោធនកម្មភាសាអង់គ្លេសដែលសិស្ស និស្សិតទទួលបាន ។

២.២ ការទទួលឱ្យចូលសិក្សា ដោយសិក្សាថ្នាក់បំប៉ន

សិស្ស និស្សិតអាចស្នើសុំបង់ថ្លៃសិក្សាថ្នាក់បំប៉នភាសាអង់គ្លេស ទៅតាមមហាវិទ្យាល័យ នីមួយៗ ដែលបានកំណត់ដោយសាកលវិទ្យាល័យ ដោយមិនតម្រូវឱ្យធ្វើវិសោធនកម្មលើចំណេះដឹងភាសាអង់គ្លេសឡើយ។

៣ - នីតិវិធីនៃការដាក់ពាក្យសុំចូលសិក្សា

៣.១ ការសុំពាក្យសុំចូលសិក្សា

សិស្ស-និស្សិត ដែលមានបំណងចុះឈ្មោះចូលសិក្សានៅសាកលវិទ្យាល័យ ត្រូវមកទំនាក់ទំនងជាមួយផ្នែកចុះឈ្មោះ និងបញ្ជិកា នៃការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីស្នើសុំចុះឈ្មោះចូលសិក្សានៅរៀងរាល់ម៉ោងធ្វើការ ។

៣.២ ឯកសារសំណុំបែបបទ

សិស្ស-និស្សិតត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

ក. សម្រាប់ថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រ

១. ពាក្យសុំ ចុះឈ្មោះចូលសិក្សា ០១ច្បាប់ ដោយមានបិតរូបថតបច្ចុប្បន្ន 4x6

២. រូបថតបច្ចុប្បន្ន 4x6 ចំនួន ផ្ទៃពណ៌ខៀវ ០៥សន្លឹក និងផ្ទៃពណ៌ស ចំនួន ០២សន្លឹក

៣. ច្បាប់ថតចម្លងសញ្ញាបត្រទុតិយភូមិ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដែលបញ្ជាក់ដោយ សាលារាជធានីភ្នំពេញ ឬសាលាខណ្ឌ ឬសមត្ថកិច្ចពាក់ព័ន្ធ ឬសញ្ញាបត្រដែលមានភ្ជាប់ QR ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិញ្ញាបនបត្រនេះតាមរយៈថ្នាលផ្ទៀងផ្ទាត់ឯកសារ Verify.gov.kh ចំនួន ០២ច្បាប់

៤. ច្បាប់ថតចម្លងសញ្ញាបត្រ ឬលិខិតបញ្ជាក់ចំណេះដឹងភាសាអង់គ្លេសដែលមានពិន្ទុ IELTS ចាប់ពី ៣.៥០ ឬ TOEFL ចាប់ពី ៣៥០ (Paper based) មិនលើសពី ២ឆ្នាំ ក្រោយពីចេញសញ្ញាបត្រ ឬលិខិតបញ្ជាក់ជាគ្រូបង្រៀនភាសាអង់គ្លេស ចំនួន ០១ច្បាប់

៥. សញ្ញាបត្រកុំព្យូទ័រ MS Word and Excel ចំនួន ០១ច្បាប់

៦. ច្បាប់ថតចំលងលទ្ធផលប្រឡងជាប់មធ្យមសិក្សាទុតិយភូមិពីវៃបសាយរបស់ក្រសួងអប់រំ យុវជន និងកីឡា (សម្រាប់សិស្សដែលបញ្ចប់ការសិក្សាចាប់ពីឆ្នាំ២០១៨ តទៅ) ចំនួន ០១ច្បាប់

៧. ឯកសារបញ្ជាក់អត្តសញ្ញាណ (ដូចជាអត្តសញ្ញាណប័ណ្ណ) ចំនួន ០១ច្បាប់

ខ. សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

១. ពាក្យសុំ ចុះឈ្មោះចូលសិក្សា ០១ច្បាប់ ដោយមានបិតរូបថតបច្ចុប្បន្ន 4x6

២. រូបថតបច្ចុប្បន្ន 4x6 ចំនួន ០៥សន្លឹក

៣. ច្បាប់ថតចម្លងសញ្ញាបត្រទុតិយភូមិ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដែលបញ្ជាក់ដោយ សាលារាជធានីភ្នំពេញ ឬសាលាខណ្ឌ ឬសមត្ថកិច្ចពាក់ព័ន្ធ ចំនួន ០២ច្បាប់

៤. ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រ ឬលិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដែលបញ្ជាក់ដោយ សាលារាជធានីភ្នំពេញ ឬសាលាខណ្ឌ ឬសមត្ថកិច្ចពាក់ព័ន្ធ ចំនួន ០២ច្បាប់

៥. ច្បាប់ថតចម្លងប្រត្តិបត្តិពិន្ទុថ្នាក់បរិញ្ញាបត្រ ចំនួន ០១ច្បាប់

៤ - ការផ្ទេរការសិក្សា

៤.១ ការផ្ទេរចូលមកសាកលវិទ្យាល័យ

និស្សិតដែលមានបំណងផ្ទេរចូលមកសិក្សានៅសាកលវិទ្យាល័យ នឹងត្រូវបានធ្វើការត្រួតពិនិត្យ និងសម្រេចដោយ គណៈកម្មការគ្រប់គ្រងកិច្ចការនិស្សិត របស់សាកលវិទ្យាល័យ ដោយអនុវត្តលក្ខខណ្ឌដូចខាងក្រោម ៖

- និស្សិត្រូវមានសញ្ញាបត្រឆ្នាំសិក្សាមូលដ្ឋាន ពីគ្រឹះស្ថានចាស់
- និស្សិតត្រូវមានព្រឹត្តិបត្តពិន្ទុសម្រាប់ឆ្នាំទី១ ពីគ្រឹះស្ថានចាស់
- កម្មវិធីសិក្សារបស់គ្រឹះស្ថានចាស់ ត្រូវប្រហាក់ប្រហែលជាមួយនឹងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ
- និស្សិតត្រូវមានពិន្ទុនិទ្ទេសចាប់ពី ២.០០ ឡើងទៅគ្រប់មុខវិជ្ជា ករណីមុខវិជ្ជាណាមួយតូចជាង ២.០០ ត្រូវសិក្សាបំពេញក្រេឌីតលើមុខវិជ្ជានោះ ជាមួយសាកលវិទ្យាល័យ
- សមាជិក-សមាជិកា គណៈកម្មការដែលមានសមាសភាពចូលរួមពីគ្រប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ មជ្ឈមណ្ឌល ការិយាល័យ និងផ្នែកដែលពាក់ព័ន្ធ សិក្សាពិន្ទុនិទ្ទេសលើមុខវិជ្ជាជំនាញនីមួយៗ ដើម្បីវាយតម្លៃ ថាពិតជាមានសមត្ថភាពអាចសិក្សាតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ បាន និងប្រគល់មកគណៈកម្ម ការ ដើម្បីប្រជុំសម្រេច
- គណៈកម្មការគ្រប់គ្រងកិច្ចការនិស្សិត ធ្វើការប្រជុំទៅលើការអនុញ្ញាតឱ្យផ្ទេរចូល មកសិក្សានៅសាកលវិទ្យាល័យ ទៅតាមលទ្ធផលនៃការវាយតម្លៃរបស់មហាវិទ្យាល័យ និង លក្ខខណ្ឌផ្សេងៗ របស់សាកលវិទ្យាល័យ។

៥ - ការដកឈ្មោះចេញពីការសិក្សា និងចុះឈ្មោះសារជាថ្មី

៥.១ ការដកឈ្មោះចេញពីការសិក្សា

សាកលវិទ្យាល័យនឹងចាត់ទុកថា និស្សិតបានបោះបង់ចោលការសិក្សាក្នុងករណីនិស្សិត (ចាស់និងថ្មី) មិនមានវត្តមានចូលសិក្សារយៈពេល១៥ថ្ងៃ (នៃថ្ងៃធ្វើការ) ជាប់គ្នាដោយគ្មានការជូនដំណឹង។

៥.២ ការចុះឈ្មោះសារជាថ្មី

និស្សិតដែលបានស្នើសុំព្យួរការសិក្សា សាកលវិទ្យាល័យបានផ្តល់សិទ្ធិត្រឡប់វិញ រយៈពេល ២ឆមាស បន្ទាប់ពីការព្យួរការសិក្សា ប៉ុន្តែនិស្សិតតម្រូវឱ្យធ្វើការស្នើសុំចុះឈ្មោះជាថ្មីម្តងទៀត ទៅតាមនីតិវិធី របស់ការិយាល័យសិក្សា និងកិច្ចការនិស្សិត ដើម្បីជូនដំណឹងថាបានត្រឡប់មកសិក្សាវិញ។

ហិរញ្ញវត្ថុ

១. គោលការណ៍ និងនីតិវិធីបង់ថ្លៃសិក្សា

ផ្នែកគណនេយ្យ និងប្រតិបត្តិការ នៃការិយាល័យផែនការ និងហិរញ្ញវត្ថុ ទទួលការបង់ថ្លៃសិក្សារបស់សិស្ស-និស្សិត ដែលមានជាច្រើនជម្រើស តាមតារាងតម្លៃដែលបានអនុម័តដោយ គណៈកម្មាធិការកំណត់ថ្លៃរបស់សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

១.១ លក្ខខណ្ឌបង់ថ្លៃសិក្សា

<u>និស្សិតថ្មី</u>

និស្សិត ត្រូវធ្វើការបង់ថ្លៃសិក្សា ឱ្យបានមុនកាលបរិច្ឆេទចូលសិក្សា និង/ឬថ្លៃសេវារដ្ឋបាលផ្សេងៗទៀតដោយយោងទៅតាមការកំណត់របស់សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា។

<u>និស្សិតចាស់</u>

និស្សិត អាចធ្វើការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗទៀត (សម្រាប់ឆមាសថ្មី) ចាប់ពីថ្ងៃប្រកាសលទ្ធផលឆមាសចាស់ រហូតដល់១៥ថ្ងៃ (រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក) ក្រោយពេលឆមាសថ្មីចាប់ផ្តើម។

១.២ ជម្រើសនៃការបង់ថ្លៃសិក្សា ចាប់ពីឆ្នាំសិក្សា ២០២៣-២០២៤

និស្សិត អាចជ្រើសរើសបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ដែលសាកលវិទ្យាល័យបានកំណត់ដូចខាងក្រោម៖

- **ការបង់ថ្លៃសិក្សាពេញមួយឆ្នាំសិក្សា (Full Payment)៖** ជាការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ពេញមួយឆ្នាំសិក្សា។
- **ការបង់ថ្លៃសិក្សាមួយឆមាស (Semester Payment)៖** ជាការបង់ថ្លៃសិក្សា និង/ឬថ្លៃសេវាផ្សេងៗ ទៅតាមឆមាសសិក្សា (មួយឆ្នាំបង់ពីរដង)។
- **ការបង់ថ្លៃសិក្សាតាម៤ដំណាក់កាល (4 Installments Payment)៖**

